**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរងនិងពលទាហាន ទាំងអស់នៅក្នុងអគ្គនាយកដ្ឋានយោធសេវានៃក្រសួងការពារជាតិ សូមប្រកាសគាំទ្រជាឱឡារិក និងយ៉ាងពេញទំហឹង ចំពោះការផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់ប្រកបដោយឧត្តមគតិនិងមនសិការស្នេហាជាតិខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញនិងធម្មនុញ្ញបន្ថែមពាក់ព័ន្ធ " **ដើម្បីកំណត់ឱ្យប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាឥស្សរជនដែលមានសញ្ជាតិខ្មែរតែមួយគត់** "។

យើងខ្ញុំទាំងអស់គ្នាយល់ឃើញថា គំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់នេះ បានឆ្លុះបញ្ចាំងពីមនសិការស្នេហាជាតិមាតុភូមិ ស្មោះត្រង់ដាច់ខាតចំពោះប្រទេសជាតិនិងប្រជាពលរដ្ឋខ្មែរ ក្នុងគោលបំណងបញ្ចៀសឱ្យបានដាច់ខាតនូវការជ្រៀតជ្រែកពីបរទេសខាងក្រៅ ចូលមកកិច្ចការផ្ទៃក្នុងនៃការដឹកនាំជាតិរបស់កម្ពុជា និងជាការធានាទាំងខាងផ្លូវច្បាប់ ទាំងខាងនយោបាយ ឱ្យឥស្សរជនជាន់ខ្ពស់ ដែលកាន់មុខដំណែងជាមេដឹកនាំនៃស្ថាប័នកំពូលទាំងបួនរបស់ជាតិ ត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ចំពោះជាតិ មាតុភូមិកម្ពុជា ធ្វើការដឹកនាំប្រទេសដោយតម្កល់ឧត្តមប្រយោជន៍ជាតិជាធំ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរង និងពលទាហាន ទាំងអស់នៅក្នុងអគ្គនាយកដ្ឋានយោធសេវានៃក្រសួងការពារជាតិ សូមប្រកាសគាំទ្រដាច់ខាត ចំពោះគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតស្នេហាជាតិដ៏ឧដុង្គឧត្តម របស់ **សម្តេចតេជោ** និងសូមប្តេជ្ញាចិត្តធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីការពារឱ្យបានដាច់ខាត សន្តិភាព និងសមិទ្ធផលសង្គមជាតិ ដែលប្រសូត្រចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ។

ថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១

**អគ្គនាយក**

**នាយឧត្តមសេនីយ៍ មាស សាម៉ន**